## Discouraging someone from pursuing a course of action



### ដាក់ពាក្យសុំឈប់ពីក្រុមហ៊ុន

ប្រធាន៖ ពិសី ឮថាចង់ឈប់ធ្វើការ មានបញ្ហាអីអំ? ប្រាប់បងមើល។

ពិសី៖ ចាស បង។ ខ្ញុំចង់សាកល្បងការងារផ្សេងវិញ ព្រោះធ្វើការងារហ្នឹងយូរឆ្នាំដែរហើយ។

ប្រធាន៖ ចង់ធ្វើការអីវិញ?

ពិសី៖ ខ្ញុំចង់ធ្វើផ្នែកគណនេយ្យវិញបង។

ប្រធាន៖ អីចឹងចាំបាច់ឈប់ពីក្រុមហ៊ុនយើងធ្វើអី? បងផ្លាស់ពិសីឯងទៅធ្វើខាងគណនេយ្យវិញទៅបានហើយ។ ម៉េចដែរ? ហើយប្រាក់ខែនៅដដែល។ ធម្មតា ផ្នែកគណនេយ្យបានប្រាក់ខែតិចជាងខាងម៉ាឃីតធីង ប៉ុន្តែបើពិសីចង់ទៅខាងគណនេយ្យ ប្រាក់ខែបងឲ្យដូចឥឡូវចឹង។ ណាមួយនៅខាងនោះម៉ោងធ្វើការក៏តិចជាងឥឡូវ វាល្អម្យ៉ាងដែរសម្រាប់អូន។ អូនគិតម៉េចដែរ?

ពិសី៖ ចាស បង ហ្នឹងហើយ អីចឹងក៏បានដែរបង។ អរគុណច្រើនបង។

### ទៅញ៉ាំការនៅផ្លូវឆ្ងាយ

កូនស្រី៖ ម៉ែ ថ្ងៃសៅរ៍ហ្នឹង ខ្ញុំត្រូវទៅញ៉ាំការពួកម៉ាកនៅពោធិ៍សាត់។

ម្ដាយ៖ ងាប់ ហើយទៅឆ្ងាយម៉េះ? ខែភ្លៀងទៀត។ មិនបាច់ទៅអ៊ំផ្ញើតែចំណងដៃតាមគេទៅបានហើយ។

កូនស្រី៖ មានទៅស្អីម៉ែ។ ទៅជាមួយគេជាមួយឯងតាស។

ម្ដាយ៖ ជាមួយគេជាមួយឯងក៏ដោយ។ កុំទៅ ម៉ែអត់ឲ្យទៅអ៊ំណា។

កូនស្រី៖ គ្មានអ្នកណាគេដូចម៉ែឯងអីចឹងអ៊ំ បារម្ភខុសទំនង។

| | |
|---|---|
| ពិសី | female Cambodian name |
| ឈប់ធ្វើការ | to quit a job; equivalent: ឈប់ពីការងារ, ឈប់ពីក្រុមហ៊ុន |
| ... មើល | phrase-final: softens a command or request |
| (ផ្នែក)គណនេយ្យ | accounting (department) |
| ម៉ាឃីតធីង | marketing |
| ណាមួយ | besides |
| អីចឹងក៏បានដែរ | that works as well / that's ok as well |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ញុំាការ | [to join a] wedding ceremony |
| ពោធិ៍សាត់ | Pursat (province in western Cambodia) |
| ងាប់ | Gosh! / What! |
| ចំណងដៃ | wedding gift (e.g., an envelope with money) |
| ស្អី | colloquial form of អី or អ្វី |
| មានទៅស្អី | nothing to worry |
| ជាមួយគេជាមួយឯង | with others |
| តាស | affirmative particle |
| បារម្ភខុសទំនង | [you're] unreasonably worried |

## Cultural notes

ដោយសារនៅប្រទេសកម្ពុជាមានគ្រោះថ្នាក់ចរាចរណ៍ញឹកញាប់និងករណីចោរកម្មច្រើន ឪពុកម្ដាយភាគច្រើនមិនចង់ឲ្យកូនរបស់ខ្លួនធ្វើដំណើរផ្លូវឆ្ងាយឬធ្វើដំណើរនៅពេលយប់នោះទេ។ ទោះជាបើកបរដោយប្រុងប្រយ័ត្នក៏ដោយ ក៏អាចទទួលរងគ្រោះថ្នាក់ដោយសារអ្នកមិនគោរពច្បាប់ចរាចរណ៍ ឬអ្នកដែលពិសាគ្រឿងស្រវឹងជាអ្នកបង្ក។

| | |
|---|---|
| ចោរកម្ម | theft, banditry, robbery |
| ទទួលរង | to be a victim of |
| គ្រឿងស្រវឹង | alcohol |

## Additional dialogue

សុជាតា៖ ពិសី កំពុងមើលអីគេហ្នឹង?
ពិសី៖ កំពុងតែរកទិញថ្នាំនៀក។ គេថាព្យាបាលបានជំងឺមួយរយមុខ។
សុជាតា៖ ឯណា? ... អូ ថ្នាំហ្នឹងអេ៎។ កុំទិញល្អជាង បោកសុទ្ធ។
ពិសី៖ ម៉េចជាតាឯងដឹង? [ជាតា = short form of សុជាតា]
សុជាតា៖ ថីមិនដឹង? បើខ្ញុំធ្លាប់ទិញឲ្យម៉ាក់ខ្ញុំប្រើអស់កន្លះឆ្នាំដែរ គ្មានឃើញជាអីផង។
ពួកម៉ាកខ្ញុំម្នាក់ទៀតក៏ទិញប្រើដែរ គ្មានឃើញប្រសិទ្ធភាពអីទេ។ ឥឡូវឈប់ប្រើហើយ។
ស្ដាយលុយសឹងអី មិនមែនថោកឯណា។
ពិសី៖ មិនបាច់ទិញល្អជាងអីចឹង។

| | |
|---|---|
| ជំងឺមួយរយមុខ | all diseases |
| បោកសុទ្ធ | it's obviously a fraud/cheating |
| ថីមិនដឹង? | Why wouldn't I know? (implying that the speaker does know) |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.